**សម្ព័ន្ធដើម្បីសិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យ**

*Ligue pour les Droits de l'Homme et la Démocratie*

**សន្តិភាព សេរីភាព ភាតរភាព**

# សេចក្តីថ្លែងការណ៍របស់តំណាងសមាគមសម្ព័ន្ធដើម្បីសិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យ ក្នុងឱកាសងធីបុណ្យផ្កាសាគ្គ២៩មិនាឆ្នាំ២០១៤នៅវត្តពោធិវង្ស

ជាតំបូងខ្ញុំករុណាខ្ញុំសូមថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីគោរពសក្ការៈ សូមជំរាបសួរ លោក-តា លោក-យាយ លោក លោក-ស្រី អ្នកនាងកញ្ញា និងបងប្អូនជនរួមជាតិដោយក្តីគោរព។ ក្នុងនាមតំណាងអោយសមាគមសម្ព័ន្ធដើម្បីសិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យ **នាងខ្ញុំសូមអរព្រះគុណ**និងអរគុណបងប្អូនទាំងអស់ដែលបានមកចូលរួមក្នុងកម្មវិធិបុណ្យផ្កាសាមគ្គីគាំទ្រដល់សកម្មភាពសង្គម និងមនុស្សធម៌របស់បណ្តាញព្រះសង្ឃឯករាជដើម្បីជួយសង្គ្រោះដល់ជនរួមជាតិក្រីក្រនៅឯប្រទេសកម្ពុជាដែលកំពុងតែរងទុក្ខវេទនា រងការជិះជាន់គៀបសង្កត់បំបិទសិទ្ធិសេរីភាពនិងការបណ្តេញចេញពីដីធ្លី។ល។ ។ **វត្តមាន**របស់បងប្អូនពេលនេះគឺមានអត្ថន័យចំពោះនាងខ្ញុំក៏ដូចបងប្អូនយើងឯក្នុងស្រុកដែលកំពុងរងគ្រោះ។ វាបង្ហាញការស្រលាញ់សច្ចៈយុត្តិធម៌ ពីសាមគ្គីធម៌ ពីសប្បុរសធម៌និងពីការយកចិត្តទុកដាក់របស់បងប្អូននៅទីនេះចំពោះជនរួមជាតិយើងដែលកំពុងរងទុក្ខវេទនានិងរងការជិះជាន់នៅឯក្នុងស្រុក។ នាងខ្ញុំក៏សូមថ្លែង**អំណរគុណដល់ចៅអធិការវត្ត**និងពុទ្ធបរិស័ទវត្តពោធិវង្សទាំងអស់ដែលបានជួយសម្រួលកិច្ចការផ្សេងៗដើម្បីអោយកម្មវិធិបុណ្យនេះប្រព្រឹត្តិទៅបាន ជាពិសេសគឺអ៊ំៗចុងភៅដែលបានជួយធ្វើម្ហូបអាហារសម្រាប់វិធីបុណ្យនេះ។ ឆ្លៀតឱកាសនេះ ខ្ញុំសូមថ្លែង**អំណរគុណយ៉ាងជ្រាលជ្រៅដល់បងប្អូនខ្មែរនៅខេត្តលីយ៉ុងនិងនៅទូលូស**ដែលបានទទួលព្រះតេជគុណប៊ុត-ប៊ុនតេញ និងសកម្មជនសិទ្ធិមនុស្សពីរនាក់ទៀតដែលរួមដំណើរជាមួយព្រះអង្គយ៉ាងកក់ក្តៅនិងដោយភាតរភាពបំផុត។ **ពីពេល**នេះតទៅសមាគមសម្ព័ន្ធដើម្បីសិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យនឹងសហការណ៍គ្រប់សកម្មភាព និងការទាមទារសិទ្ធិសេរីភាពនិងលទ្ធិប្រជាធិបតេយ្យរបស់បងប្អូនជនរួមជាតិយើងទាំងអស់នៅក្នុងស្រុកក៏ដូចរបស់បណ្តាញព្រះសង្ឃឯករាជ។

**ក្រៅពីការមកថៃទាំសុខភាពនិងនាំសុខ**ទុក្ខពីបងប្អូនក្នុងប្រទេសមកជម្រាបបងប្អូនឯនាយសមុទ្រ បេសកម្មសំខាន់មួយទៀតក្នុងតំណើរទស្សកិច្ចរបស់តេជគុណប៊ុត-ប៊ុនតេញនិងសកម្មជនសិទ្ធិមនុស្សទាំងពីរនាក់ **គឺយុទ្ធនាការសុំអោយមានការ**ដោះលែងលោក វ៉ន-ពៅ លោក ថេង-សាវឿន លោក ចន្ទ-ពុទ្ធស័ក និងកម្មករ១៨នាក់ទៀតដែលកំពុងជាប់ឃុំឃាំងយ៉ាងអយុត្តិធម៌នៅត្រពាំងផ្លុង។ **ដូច្នេះខ្ញុំសូមអញ្ជើញបងប្អូនចុះហត្ថលេខាលើញត្តិ**សុំដោះលែង លោក វ៉ន-ពៅ លោក ថេង-សាវឿន លោក ចន្ទ-ពុទ្ធស័ក និងកម្មករ១៨នាក់ទៀត ដែលព្រះតេជគុណ ប៊ុត-ប៊ុនតេញនិងសកម្មជនសិទ្ធិមនុស្សនឹងនាំយកទៅប្រគល់ដោយផ្ទាល់ដៃដល់ស្ថានទូតបារាំងប្រចាំនៅកម្ពុជា ហើយញត្តិនេះយើងនឹងផ្ញើរទៅរដ្ឋមន្ត្រីនៃក្រសួងការបរទេសប្រទេសបារាំងផងដែរ។ ។ **កាលពីម្សិលមិញ អង្គការសិទ្ធិមនុស្ស**ដែលតែងធ្វើការយ៉ាងជិតស្និទ្ធជាមួយសហគមន៍ផ្សេងៗបានជួយរៀបចំការធ្វើកូដកម្មទាមទារដោះលែងលោក វ៉ន-ពៅ លោក ថេង-សាវឿន លោក ចន្ទ-ពុទ្ធស័ក និងកម្មករ១៨នាក់ទៀតរបស់សហគមន៍បឹងកក់បុរីកីឡានិងថ្មគោល។ **បេសកម្មជាអទិភាពបន្ត**ទៀតរបស់សមាគមសម្ព័ន្ធដើម្បីសិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យ របស់បងប្អូនខ្មែរក៏ដូចរបស់បណ្តាញព្រះសង្ឃគឺការទាមទារសិទ្ធិសេរីភាព និងយុត្តិធម៌ ដល់លោក វ៉ន-ពៅ លោក ថេង-សាវឿន លោក ចន្ទ-ពុទ្ធស័ក និងបងប្អូនជនរួមជាតិទាំងអស់ដែលកំពុងតែរងការជិះជាន់គាបសង្កត់បំបិទសិទ្ធិសេរីភាព។សូមអរគុណចំពោះចូលរួមទាមទាររបស់បងប្អូនជាមួយយើងខ្ញុំ។

ដោយឡែក សមាគមសម្ព័ន្ធដើម្បីសិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យក៏មានបំណងចង់ដាក់ពាក្យបណ្តឹងទៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលកើតឡើងនៅកម្ពុជា។ ខ្ញុំដឹងថា មានចលនាមួយចំនួនបានប្រកាសថា បានដាក់ពាក្យបណ្តឹងហើយរួមទាំងគណបក្សនយោបាយផងដែរ តែបើតាមខ្ញុំដឹង ទាំងនេះ

សុទ្ធតែរឿងមិនច្បាស់លាស់។ ទើបតែថ្មីៗនេះលោក Richard Rogers មេធាវីតំណាងអោយជនរងគ្រោះនិងអង្គការសិទ្ធិមនុស្ស ចំនួន២០និងលោកMorton Sklar មេធាវីនៃសម្ព័ន្ធសិទ្ធិមនុស្សនិងអ្នកតស៊ូមតិដើម្បីលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាបានដាក់ពាក្យ បណ្តឹងពីរផ្សេងគ្នាប្តឹងលោកហ៊ុនសែននិងមន្ត្រីមួយចំនួនទៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិពីបទប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្ម ប្រឆាំងនឹងមនុស្សជាតិ។ សមាគមសម្ព័ន្ធដើម្បីសិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យចង់ដាក់បណ្តឹងដោយផ្ទាល់ឬក៏អាចសហការ ជាមួយលោក Morton Sklar ឬលោក Richard Rogers ដើម្បីជម្រុញករណីនេះអោយរិតតែលឿននិងមានប្រសិទ្ធិភាព ។ តែនេះ គ្រាន់តែជាគម្រោងតែប៉ុណ្ណោះដោយយើងខ្វះមធ្យោបាយ។ សូមអរគុណ..